នីវរណៈ៥ និង សមាធិ

	នីវរណធម៌	អារហារនៃនីវរណធម៌	ធម៌ បដិបក្ខនឹងនីវរណ	អារហារនៃធម៌ដែលផ្ទុយនឹងនីវរណ	ធម៌លះនីវរណ	អង្គឈានដែលដុត
១	កាមឆន្ទ	សុភនិមិត្ត	អលោភ	អសុភនិមិត្ត	នេក្ខម្ម	ឯកគ្គតា
២	ព្យាបាទ	បដិឃនិមិត្ត	អទោស	មេត្តា	អព្យាបាទ	បីតិ
៣	ថីនមិទ្ធ	អរតិ, តន្ទិ, វិជម្ភិតា, ភត្តសម្មទោ, លីនត្តំ	កាយលហុតា ចិត្តលហុតា	អារម្ភធាតុ, និក្កមធាតុ បរក្កមធាតុ	អាលោកសញ្ញា	វិតក្ក
៤	ឧទ្ធច្ច កុក្កុច្ច	អវូបសមោ, អយោនិសោមនសិការ	កាយបស្សទ្ធិ ចិត្តបស្សទ្ធិ	ចេតសោវូបសម	អវិក្ខេប	សុខ
៥	វិចិកិច្ឆា	អយោនិសោមនសិការ	អធិមោក្ខ	យោនិសោមនសិការ	ធម្មវវត្ថាន	វិចារ

អរតិ(ធុញទ្រាន់), **តន្ទិ**(ខ្ជិល,ដេកលក់), **វិជម្ភិតា**(មិនពុតកាយ), **ភត្តសម្មទោ**(ពុលបាយ), **លីនត្តំ**(រួញរា), **អវូបសមោ**(មិនស្ងប់ចិត្ត), **អយោនិសោមនសិការ**(ធ្វើទុកក្នុងចិត្តដោយឧបាយខុសទំនង)	**អារម្ភ**(ប្រារព្ធព្យាយាម), **និក្កម** = **និ** + **កម** =exertion, strength, endurance។ **បរក្កម** =) **បរ**កម + + **អ** = ឈានទៅខាងមុខ, ជំនះ), **ចេតសោ**(ដោយចិត្ត), **វូបសម** (=**វិ** + **ឧប** + **សម** = ចូលទៅរម្ងាប់)

១-កាមឆន្ទៈ = **កាម** + **ឆន្ទ** = សេចក្តីពេញចិត្តក្នុងកាម។ ជំពាក់ជាប់ចិត្តនឹងកាម។

កាម = **កម**(ដើរទៅរក)+**ណ** = ចំណង់

ឆន្ទ = ធម៌ដែលធ្វើចិត្តឲ្យមានអង្គពេញកម្លាំង (ដូចមេទ័ព ទាំង៤ ក្នុងចតុរង្គសេនា)។

ប្រៀបដូចទឹកដែលមានលាយពណ៌ ។ ប្រៀបដូចជាអ្នកជំពាក់បំណុលគេ។ (បិដកលេខ១៤ ទំព័រ ១៨១)។

២-ព្យាបាទៈ = **វ**យ(វិនាស)+**អា**+**បទ**(ស្នាមជើង,ផ្លូវ) = កំហឹង, គំនុំ, ដំណើរចងចិត្តនឹងធ្វើអ្នកដ៏ទៃឲ្យវិនាស។

ប្រៀបដូចទឹកដែលក្តៅពុះកញ្ជ្រោល ។ ប្រៀបដូចជាអ្នកមានជម្ងឺ ។

៣-ថីនមិទ្ធៈ = **ថីន**(សេចក្តីរួញរានៃចិត្ត) + **មិទ្ធ**(សេចក្តីងោកងុយ) = ដំណើរច្រអូសនិងងុយដេក, ចិត្តធ្ងន់ស្ទក់មិនរហ័ស ។

ប្រៀបដូចទឹកដែលគ្រោបដោយសាវាយ និង ស្លែ ។ ប្រៀបដូចជាអ្នកជាប់គុក ។

៤-ឧទ្ធច្ចកុក្កុច្ចៈ = **ឧទ្ធច្ច**(សេចក្តីរាយមាយ)+ **កុក្កុច្ច**(សេចក្តីក្តៅក្រហាយស្តាយក្រោយ) = សេចក្តីរាយមាយក្តៅក្រហាយ។

ប្រៀបដូចទឹកដែលមានរលកដោយខ្យល់បក់ ។ ប្រៀបដូចជាអ្នកបម្រើគេ ។

៥-វិចិកិច្ឆា = សេចក្តីសង្ស័យមិនដាច់ស្រាច់ ។

ប្រៀបដូចទឹកដែលកករល្អក់ ។ ប្រៀបដូចជាបុរសមានទ្រព្យមានតម្លៃ ដើរផ្លូវឆ្ងាយគ្មានស្បៀងអាហារ និង សម្ប្បរដោយចោរប្លន់ ។

១-អលោភៈ = សេចក្តីមិនជាប់ជំពាក់អារម្មណ៍ក្នុងចិត្ត។ ដូចជាទឹកមិនជាប់នឹងស្លឹកឈូក ។

២-អទោសៈ = មិនកាច, មិនខឹង, មិនប្រកាន់, មិនគុំ។

៣-កាយលហុតា និង **ចិត្តលហុតា** (**លហុ** = ស្រាល, រហ័ស, រួសរាន់) = ភាពស្រាលនិងរហ័សរហួនរបស់ចិត្តនិងកាយ។

៤-កាយបស្សទ្ធិ និង **ចិត្តបស្សទ្ធិ** = ((**បស្សទ្ធ=ប+សំភ+ត, ត→ទ្ធ, ស→ស្ស**, លុបនិគ្គហិត) = សូប់រម្ងាប់ហើយ) = កាយនិងចិត្តដែលសូប់រម្ងាប់ហើយ។ សេចក្តីសូប់នៃកាយនិងចិត្ត។

៥-អធិមោក្ខៈ = សន្និដ្ឋាន, ការជឿស៊ប់នៃចិត្ត ។ សទ្ធា = ជ្រះថ្លានិងជឿតែចំពោះកុសលធម៌ ។ អធិមោក្ខ អាចកើតឡើងទាំងជាមួយកុសលធម៌ និង ទាំងជាមួយអកុសលធម៌។ អធិមោក្ខ មិនមាននៅក្នុង វិចិកិច្ឆា និង ទ្វិបញ្ចទ្វារវជ្ជនចិត្ត ទេ។

១-នេក្ខម្ម: (**និ+កម+ណ**) =ការចេញចាកកាម, ការចេញបួស។ **មិនជាប់ជំពាក់ក្នុងកាម** ។

២-អព្យាបាទ(**ន+ព្យាបាទ**)=មិនធ្វើប្រយោជន៍និងសុខឲ្យវិនាស, ការមិនគុំគួន ។

៣-អាលោកសញ្ញា (**អាលោក** (=**ឱកាស**=ពន្លឺ + **សញ្ញា**) = ការមានពន្លឺជាសញ្ញា ។

៤-អវិក្ខេប: (**ន+វិ+ឝិប+ណ**) = ការមិនរាយមាយ។

៥-ធម្មដ្ឋតាន:(**ធម្ម+ឋិ+អវ+ស្ត**)(**វត្តាន**=resolution, determination=និមិត្ត=ការកំណត់ដឹង)= ការមានធម្មនិមិត្ត។

១-ឯកគ្គតា = មានអារម្មណ៍ជាឯក, ចិត្តមានអារម្មណ៍តែមួយ ។

២-បីតិ = ធ្វើចិត្តឲ្យសប្បាយនឹងអារម្មណ៍ (ទោសមូលចិត្ត, វិចិកិច្ឆា និង ឧទ្ធច្ចមូលចិត្ត មិនមានបីតិ)។ ធម្មជាតិញ៉ាំងកាយនិងចិត្តឲ្យឆ្អែតមិនឲ្យឃ្លាន។ **ព្រះត្រៃបិដកលេខ ២៥ ទំព័រ ២៥៥៖**

- ភ្លើងឆេះឡើងព្រោះអាស្រ័យស្មៅ និង ឧស ជាកំញម = បីតិ ដែលកើតឡើងព្រោះអាស្រ័យ នូវកាមគុណទាំង ៥។
- បុគ្គលមិនអាចធ្វើភ្លើងឲ្យឆេះកើតឡើងបាន ដោយមិនអាស្រ័យកំញមទេ លើកលែងតែបុគ្គលមានឫទ្ធ។ ភ្លើងឆេះឡើងបានដោយអាស្រ័យឫទ្ធ = **បីតិ**ដែលកើតឡើងព្រោះអាស្រ័យឈាន និង មិនអាស្រ័យកាមគុណទាំង៥ឡើយ ។

៣-វិតក្ក: =ត្រិះរិះឡើងកាន់អារម្មណ៍, ស្ទុះទៅកាន់អារម្មណ៍ ដូច សេះស្ទុះទៅកាន់ទីដៅ។

៤-សុខ: = សុខ(ក្នុងកាយ) និង សោមនស្ស(ក្នុងចិត្ត) វេទនា។

៥-វិចារ: = សេចក្តីពិចារណានូវអារាម្មណ៍ដោយស្មើ (រក្សាចិត្តគិតទៅរកអារម្មណ៍តែមួយដោយស្មើ)។

បឋមជ្ឈាន អស់ទៅនីវរណៈទាំង៥។ ធ្វើឲ្យករជកាយ ជោគជាំ ឲ្យស្តប់ស្តល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយ ដោយ បីតិ និង សុខៈ។ ដូចជាការាយលំអិតសម្រាប់ងូត ក្នុងផ្តីលសំរិទ្ធិ លំអិតសម្រាប់ងូតក៏រលាយទៅដោយទឹកជ្រួត ជ្រាបទៅក្នុងទឹកមិនមានសល់ ។

ទុតិយជ្ឈាន រម្ងាប់ វិតក្កៈ និង វិចារៈ នាំឲ្យករជកាយ ស្តប់ស្តល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយ ដោយបីតិ និង សុខៈ ។ ដូចជាអន្លង់ទឹកដ៏ជ្រៅ មានទឹកជោរឡើង។ មុខទឹក ក្នុងទិសខាងកើត, លិច, ជើង, ត្បូង មិនមាន ។ កាលបើ ភ្លៀងបង្អោធារទឹកស្រួលសព្វៗកាលទៅ ក៏ស្រាប់តែទឹកត្រជាក់ជោរឡើង អំពីអន្លង់ទឹកនោះហើយញាំងអន្លង់ទឹក នោះឯង ឲ្យជោគជាំ ឲ្យពេញពោរ ឲ្យពេញប្រៀប ឲ្យហូរហៀដោយទឹកត្រជាក់ ។

តតិយជ្ឈាន ប្រាស់ចាកបីតិ ប្រកបដោយឧបេក្ខា និង សតិសម្បជញ្ញៈ (សម្បជាន = សំ+ប+ញា+យុ = ដឹងច្បាស់, ដឹងប្រពៃ) ញាំងករជកាយ ឲ្យស្តប់ស្តល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយ ដោយសុខៈដែលប្រាសចាកបីតិ ។ ដូចជា ផ្កាជលជាតិ (ព្រលិត, ឈូក) ដុះក្នុងទឹក ចំរើនក្នុងទឹក លូតលាស់តាមទឹក លិចទៅក្នុងទឹក ជោគជាំ ឆ្អែតស្តប់ស្តល់ បរិបូរណ៌ ផ្សព្វផ្សាយដោយទឹកត្រជាក់ រហូតដល់ចុងនិងគល់ ។

ចតុត្ថជ្ឈាន លះបង់នូវសុខផង ទុក្ខផង រំលត់សោមនស្ស និង ទោមនស្ស ក្នុងកាលមុនផង ក៏ដល់នូវចតុត្ថជ្ឈាន មិនទុក្ខមិនសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ។ ក៏ញាំងករជកាយ ឲ្យផ្សព្វផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់ ។ ដូចជា បុរសយកសំពត់សដណ្តប់កាយព្រមទាំងក្បាលអង្គុយនៅ ប្រទេសបន្តិចបន្តួច នៃករជកាយទាំងអស់ របស់ បុរសនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយសំពត់សនោះគ្មាន ។